ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / 04 / 2013
ម៉ោង (Time/Heure): 16:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន**
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យូរ ឧត្តរា**

កាលបរិច្ឆេទ: ថ្ងៃទី២៦ ខែ មេសា ឆ្នាំ ២០១៣
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើសំណើសុំដោះលែង លោក ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីការពារក្តីជនជាប់ចោទ**
គង់ សំអុន
Arthur VERCKEN
Jacques VERGÈS
Anta GUISSÉ

## ១. សេចក្តីផ្តើម

1. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើសុំដោះលែងលោក ខៀវ សំផន ឱ្យនៅក្រៅឃុំជាបន្ទាន់ ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣[1]។ បន្ទាប់ពីទទួលបានទូវសំណើសុំនេះ អង្គជំនុំជម្រះសាលាដំបូងបានកំណត់កាលបរិច្ឆេទសវនាការ នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និងបានបង្គាប់ឱ្យសហព្រះរាជអាជ្ញាធ្វើការឆ្លើយតបដោយផ្ទាល់មាត់ទៅនឹងសំណើសុំនេះនៅក្នុងសវនាការ។ ដោយសារតែក្រុមមេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់ថា ខ្លួនមិនមានលទ្ធភាពចូលរួមសវនាការបាន នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទសវនាការសារជាថ្មី ទៅធ្វើនៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ វិញ។ ក្រោយពីបានពិចារណាលើសំណើសុំជាលាយលក្ខណ៍អក្សររបស់ក្រុមមេធាវីការពារក្តី និង សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់សហព្រះរាជអាជ្ញា និងរបស់ភាគីទាំងអស់ កាលពីថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសម្រេច ចេញសេចក្តីសម្រេចនេះ។

## ២. សាវតារនីតិវិធី

2. នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ជនជាប់ចោទ ខៀវ សំផន ត្រូវបានឃុំខ្លួនតាមរយៈដីការបស់សហចៅក្រមស៊ើបអង្កេត និងត្រូវបានបញ្ជូនទៅកាន់មន្ទីរឃុំឃាំងរបស់ អ.វ.ត.ក[2]។ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចបន្តឃុំខ្លួនជនជាប់ចោទម្តងហើយម្តងទៀត ហើយដីកាទាំងនោះត្រូវបានតម្កល់ដោយអង្គបុរេជំនុំជម្រះ[3]។

---

[1] សំណើសុំដោះលែងលោក ខៀវ សំផន ឱ្យនៅក្រៅឃុំជាបន្ទាន់ ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឯកសារលេខ E275 ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ("សំណើសុំឱ្យដោះលែងជាបន្ទាន់")។

[2] ដីកាសម្រេចឃុំខ្លួន ខៀវ សំផន ឯកសារលេខ C27 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[3] សូមមើល ឧទាហរណ៍ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ឯកសារលេខ C26/5/26 ចុះថ្ងៃទី ៣ ខែ កក្កដា ឆ្នាំ ២០០៩ ("សាលដីការបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍សុំដោះលែងឱ្យមានសេរីភាព") កថាខណ្ឌ ៥៣ ដល់ ៥៨ និង ៦៣។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ឯកសារលេខ C26/9/12 ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១០ ("សាលដីកាទីពីររបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍សុំដោះលែងឱ្យមានសេរីភាព") កថាខណ្ឌ ៣៤, ៣៥ , ៣៨ និង ៣៩។

3. នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ នៅក្នុងសំណុំរឿង ០០២ និងបានចេញដីកាបង្គាប់ឃុំខ្លួនបណ្ដោះអាសន្នជនជាប់ចោទ ខៀវ សំផន ជាបន្តរហូតដល់ពេលនាំខ្លួនគាត់មកបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយបានលើកឡើងថា លក្ខខណ្ឌនានានៅក្នុងវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុងដែលបានធ្វើយុត្តិកម្មដល់ការឃុំខ្លួន ត្រូវបានបំពេញ[4]។ ជនជាប់ចោទ ខៀវ សំផន បានប្ដឹងឧទ្ធរណ៍លើការបង្គាប់ឱ្យឃុំខ្លួនដែលមាននៅក្នុងដីកាដំណោះស្រាយ[5]។

4. នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទលើដីកាដំណោះស្រាយ ដោយប្រកាសថា បណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទមិនអាចទទួលយកបាន និងបង្គាប់ឱ្យបន្តការឃុំខ្លួនជនជាប់ចោទតទៅទៀត រហូតដល់ពេលនាំខ្លួនមកបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[6]។

5. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០២ នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។ នៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១១ ជនជាប់ចោទបានដាក់សំណើសុំដោះលែងជាបណ្ដោះអាសន្ន និងនៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចដោយបដិសេធលើសំណើសុំនេះ[7]។ នៅក្នុងសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះបានយល់ឃើញថា ការដែល ខៀវ សំផន អាចប្រឈមនឹងការផ្ដន្ទាទោសធ្ងន់ធ្ងរ ប្រសិនបើតុលាការរកឃើញថាគាត់មានពិរុទ្ធនោះ ផ្ដល់នូវការជំរុញមួយ ក្នុងការរត់គេចខ្លួន និងថា ការបន្តឃុំឃាំងគឺជាការចាំបាច់ ដើម្បីធានាថាឱ្យមានវត្តមានរបស់គាត់នៅគ្រប់ដំណាក់កាលនៃសវនាការ[8]។ នៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១

---

[4] ដីកាដំណោះស្រាយ ឯកសារលេខ D427 ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ "ផ្នែក ៦៖ ការរក្សាការឃុំខ្លួន" កថាខណ្ឌ ១៦២២។

[5] សេចក្ដីជូនដំណឹងបណ្ដឹងឧទ្ធរណ៍ ឯកសារលេខ D427/4 ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១០។ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយឯកសារលេខ D427/4/3 ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១០។

[6] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/4/14 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។ សូមមើលផងដែរ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារលេខ D427/4/15 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១។

[7] សំណើសុំដោះលែងឱ្យមានសេរីភាព យោងតាមវិធាន ៨២(៣) នៃវិធានផ្ទៃក្នុង ឯកសារលេខ E18 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១១។

[8] សេចក្ដីសម្រេចលើសំណើសុំដោះលែងបន្ទាន់ របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ឯកសារលេខ E50 ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៤០។

អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានតម្កល់ទុកនូវ ការឃុំខ្លួនជនជាប់ចោទជាបន្តទៀត ដោយផ្អែកលើហានិភ័យដែលថា ជនជាប់ចោទ អាចនឹងមិនមានវត្តមាននៅក្នុងដំណាក់កាលជំនុំជម្រះ[9]។

6. នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ក្នុងអំឡុងពេលសវនាការ បន្ទាប់ពីការចេញសេចក្តីសម្រេចរបស់ អ.ជ.ត.ក ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានប្រកាសថា ខ្លួននឹងដាក់សំណើសុំឱ្យដោះលែងជនជាប់ចោទ ក្នុងពេលឆាប់ៗ[10]។ បន្ទាប់ពីមានការប្រកាសនេះរួចមក ក្រុមមេធាវីការពារក្តីបានដាក់សំណើសុំឱ្យដោះលែងបន្ទាន់ នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣។

## ៣. សារណា

7. ក្រុមមេធាវីការពារក្តី ខៀវ សំផន លើកឡើងថា ការបន្តការឃុំខ្លួនបណ្តោះអាសន្នជនជាប់ចោទ គឺមានរយៈពេលយូរហួសប្រមាណ និងរំលោភលើសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទផងដែរ។ ហានិភ័យទាំងឡាយដែលបានធ្វើយុត្តិកម្មតាំងពីដំបូងលើការឃុំខ្លួនបណ្តោះអាសន្ន ខៀវ សំផន បច្ចុប្បន្ននេះ មានតិចតួចបំផុត ឬគ្មានតែម្តង និងអាចត្រូវបានបន្ធូរបន្ថយតាមរយៈការដាក់ជនជាប់ចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ យោងតាមវិធាន ៦៥ នៃវិធានផ្ទៃក្នុង[11]។ ហេតុដូច្នេះ ក្រុមមេធាវីការពារក្តីស្នើសុំឱ្យមានការដោះលែងជនជាប់ចោទភ្លាម ដោយដាក់គាត់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[12]។

---

[9] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ឯកសារលេខ E50/3/1/4 ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ៥៤ ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ")។

[10] ប្រតិចារឹក ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E1/172.1 ទំព័រ ៥៤។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០១ (ឯកសារលេខ E163/5/1/13) ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[11] អង្គជំនុំជម្រះកត់សម្គាល់ថា "*demande de mise en liberté immédiate avec placement sous contôle judiciaire*" ជាភាសាបារាំង ឬ "*សំណើសុំដោះលែងឱ្យនៅក្រៅឃុំជាបន្ទាន់ដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ*" ជាភាសាខ្មែរ មានន័យស្មើគ្នាទៅនឹង *release on bail* ជាភាសាអង់គ្លេស (សូមមើលយោងទៅវិធាន ៦៥ នៃវិធានផ្ទៃក្នុង)។

[12] សំណើសុំឱ្យដោះលែងជាបន្ទាន់ កថាខណ្ឌ ៦៤, ៦៥។ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៦៤។

8. ក្រុមមេធាវីការពារក្តីលើកឡើងថា ភាពមិនសមទំនងដែលថាអង្គជំនុំជម្រះសាលាដំបូងនឹងចេញសេចក្តីសម្រេចនៅពេលឆាប់ៗនេះ នឹងនាំឱ្យការឃុំខ្លួនមានរយៈពេលយូរហួសប្រមាណ ដោយរំលោភលើសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ ក្នុងការទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ និងឆាប់រហ័ស[13]។ ក្រុមមេធាវីការពារក្តីកត់សម្គាល់ឃើញថា ចាប់តាំងពីមានការបង្កើត អ.វ.ត.ក នៅក្នុងឆ្នាំ ២០០៤ មក ជនជាប់ចោទ ខៀវ សំផន មិនដែលនឹកគិតចង់រត់គេចខ្លួននោះទេ និង តែងតែបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីជានិច្ច នៅពេលតុលាការត្រូវការ[14]។ ក្រុមមេធាវីការពារក្តីអះអាងថា វាក៏មិនសមទំនងផងដែរ ដែលថា ខៀវ សំផន នឹងត្រូវបានរារាំងមិនចូលរួមសវនាការដោយសារមូលហេតុសុខភាពទន់ខ្សោយនោះ[15]។ ក្រុមមេធាវីការពារក្តីលើកឡើងថា ពុំមានហានិភ័យទាល់តែសោះ ឬពុំមានហានិភ័យតូចតាចណាមួយកើតឡើងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈនោះទេ ប្រសិនបើជនជាប់ចោទត្រូវបានដោះលែងជាបណ្តោះអាសន្ន៖ ដែលនេះជាសេចក្តីសន្និដ្ឋានដែលត្រូវបានអះអាងបញ្ជាក់ដោយ អ.ជ.ត.ក នៅក្នុងសាលដីកាថ្មីៗនេះពាក់ព័ន្ធនឹងសហជនជាប់ចោទ[16]។ ក្រុមមេធាវីការពារក្តីបានគូសបញ្ជាក់បន្ថែមទៀតថា វ័យចាស់ជរារបស់ជនជាប់ចោទ ក៏ជាមូលដ្ឋានមួយសម្រាប់ធ្វើការដោះលែងផងដែរ និងថា ជនជាប់ចោទពុំបានជួបប្រទះទៅនឹងការគំរាមកំហែងទៅលើសុវត្ថិភាពរបស់គាត់នៅដំណាក់កាលណាមួយនៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធីឡើយ[17]។

---

[13] សំណើសុំឱ្យដោះលែងជាបន្ទាន់ កថាខណ្ឌ ២០។ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៥៨-៦០, ៦៤-៦៥។

[14] សំណើសុំឱ្យដោះលែងជាបន្ទាន់ កថាខណ្ឌ ២៨។ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៥៨-៥៩, ៦១, ៨៥-៨៦។

[15] សំណើសុំឱ្យដោះលែងជាបន្ទាន់ កថាខណ្ឌ ១២។

[16] សំណើសុំឱ្យដោះលែងជាបន្ទាន់ កថាខណ្ឌ ៣២-៣៥។ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៦១-៦២។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំង នឹងសេចក្តីសម្រេច របស់ អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែង ជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ឯកសារលេខ E138/1/10/1/5/7 ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៧៥ ("ត្រូវបានកត់សម្គាល់ឃើញថា ទំនងជាបង្ហាញថាគ្មានការគំរាមកំហែងពិសេសណាមួយទៅលើសុវត្ថិភាពរបស់ជនជនជាប់ចោទនោះទេ")។

[17] សំណើសុំឱ្យដោះលែងជាបន្ទាន់ កថាខណ្ឌ ២៦ និង៤០។ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៥៨, ៦២-៦៣។

9. ក្នុងការគាំទ្រសំណើរបស់ពួកគាត់ស្នើសុំដោះលែងជនជាប់ចោទជាបណ្តោះអាសន្ន ដោយស្ថិតនៅក្រោមលក្ខខណ្ឌសមស្រប និងមានសមាមាត្រ មេធាវីការពារក្តី ខៀវ សំផន ស្នើឡើងនៅក្នុងឧបសម្ព័ន្ធភ្ជាប់ទៅនឹងពាក្យសុំនោះថា ជនជាប់ចោទរស់នៅជាមួយក្រុមគ្រួសាររបស់គាត់នៅពេលដោះលែងរូបគាត់[18]។ សាច់ញាតិទាំងនេះអះអាងថា ពួកគាត់មានមធ្យោបាយ និងឆន្ទៈក្នុងការមើលថែទាំជនជាប់ចោទ[19]។ ចុងក្រោយ មេធាវីការពារក្តីស្នើឡើងថា ប្រសិនបើសំណើសុំដោះលែងជនជាប់ចោទ ខៀវ សំផន ជាបន្ទាន់ ត្រូវបានយល់ព្រមនោះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះអំពីបញ្ហានេះ គួរតែចេញជាសាធារណៈ[20]។

10. សហព្រះរាជអាជ្ញាជំទាស់ទៅនឹងពាក្យសុំដោះលែងជនជាប់ចោទជាបន្ទាន់នេះ និងបានលើកឡើងថា យុត្តិកម្មមុនៗសម្រាប់ការបន្តការឃុំខ្លួនគាត់នៅមានសុពលភាព[21]។ ពួកគាត់អះអាងថា អំណះអំណាងរបស់មេធាវីការពារក្តី ទាក់ទិននឹងរយៈពេលយូរហួសប្រមាណនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ននេះ ពុំមានទម្ងន់ណាមួយឡើយ[22]។ ពាក់ព័ន្ធនឹងបញ្ហានេះ សហព្រះរាជអាជ្ញាអះអាងថា អង្គជំនុំជម្រះសាលាដំបូងគួរធ្វើការវាយតម្លៃថាតើ រយៈពេលនៃការឃុំខ្លួនជនជាប់ចោទសមាមាត្រទៅនឹងកាលៈទេសៈនៃរឿងក្តីនេះដែរឬទេ[23]។ សហព្រះរាជអាជ្ញាអះអាងថា ដោយពិចារណាលើវិសាលភាពនៃសំណុំរឿង ០០២ ការកន្លងផុតទៅនៃពេលវេលាចាប់តាំងពីមានការចោទប្រកាន់អំពីឧក្រិដ្ឋកម្មនានា ចំនួននៃភ័ស្តុតាង ភាពស្មុគស្មាញនៃសេចក្តីសន្និដ្ឋានលើអង្គច្បាប់ និងចំនួននៃ

---

[18] ពាក្យសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៥០។ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៦៤-៦៥។

[19] លិខិតបញ្ជាក់របស់ [កោសលុប] ឯកសារ E275.2 ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣។ លិខិតបញ្ជាក់របស់ [កោសលុប] ឯកសារ E275.3 ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៣។ លិខិតធានាវត្តមាន ឯកសារ E275.4 ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣។ លិខិតបញ្ជាក់ [កោសលុប] ឯកសារ E275.7 ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣។ សៀវភៅគ្រួសារ [កោសលុប] ឯកសារ E275.8 ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣។ សូមមើលផងដែរ ពាក្យសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៦១។ ប្រតិចារឹក ចុះថ្ងៃទី១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៦៤-៦៩ (ដែលអះអាងថា ការចេញសេចក្តីសម្រេចនេះជាឯកសារសាធារណៈ អាចជួយធានាដល់សណ្តាប់ធ្នាប់សាធារណៈ)។

[20] ពាក្យសុំដោះលែងជាបន្ទាន់ កថាខណ្ឌ ៦៣។

[21] ប្រតិចារឹក ចុះថ្ងៃទី១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៧០-៧១ ។

[22] ប្រតិចារឹក ចុះថ្ងៃទី១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៧១, ៧៣។

[23] ប្រតិចារឹក ចុះថ្ងៃទី១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៧២-៧៣។

ការជំទាស់តវ៉ា និងទម្លាក់ករណីផ្លូវច្បាប់ ដែលភាគីទាំងអស់បានដាក់នោះ ពុំមានការពន្យារពេល ដែលមិនសមស្របនៅក្នុងការអនុវត្តកិច្ចដំណើរការនីតិវិធីឡើយ[24]។

11. សហព្រះរាជអាជ្ញាក៏បានអះអាងថា ឯកសារនៅក្នុងសំណុំរឿង បង្ហាញថា ការដោះលែង ខៀវ សំផន អាចបង្កឱ្យមានហានិភ័យជាក់ស្តែងមួយដែលអាចមានជាការគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ការត្រូវរួវគ្នាជាមួយអ្នកសមគំនិត ឬអ្នកសមគំនិតដែលត្រូវបានចោទប្រកាន់ ហើយ ថា វានឹងអាចប៉ះពាល់ដល់ភ័ស្តុតាង[25]។ សហព្រះរាជអាជ្ញាអះអាងទៀតថា មានមូលហេតុ ដែលមានមូលដ្ឋានរឹងមាំ ដើម្បីឱ្យជឿជាក់ថា ជនជាប់ចោទអាចបានប្រព្រឹត្តឧក្រិដ្ឋកម្មមួយ ឬ ឧក្រិដ្ឋកម្មច្រើនដែលត្រូវបានចោទប្រកាន់ ប្រឆាំងនឹងរូបគាត់ – នេះជាកត្តាមួយដែលមានចែងនៅ ក្នុងវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង ថាជាយុត្តិកម្មសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន ហើយ ដែលពាក្យសុំឱ្យដោះលែងនៅក្រៅឃុំជាបន្ទាន់នោះពុំបានលើកយកមកជំទាស់តវ៉ាឡើយ[26]។

12. សហព្រះរាជអាជ្ញាអះអាងថា វិធានការដើម្បីការពារសន្តិសុខជនជាប់ចោទ ដែលជាកត្តាមួយ មានចែងនៅក្នុងវិធាន ៦៣(៣)(ខ)(៤) នៃវិធានផ្ទៃក្នុង និងដែលត្រូវបានពិចារណាដោយអង្គបុរេ ជំនុំជម្រះ ក្នុងការផ្តល់យុត្តិកម្មលើការឃុំខ្លួនបណ្តោះអាសន្ន ក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១០ នោះ នៅតែជាការចាំបាច់[27]។ ការអនុញ្ញាតឱ្យជនជាប់ចោទនៅក្រៅឃុំនៅដំណាក់កាលនៃកិច្ចដំណើរការ នីតិវិធីនេះ អាចបង្កឱ្យមានហានិភ័យដែលមិនអាចទទួលយកបានដល់សុវត្ថិភាពរបស់ជនជាប់ចោទ ព្រមទាំងធ្វើឱ្យអន្តរាយដល់វត្តមានរបស់គាត់នៅពេលសវនាការ និងការបញ្ចប់កិច្ចដំណើរការ នីតិវិធីរបស់អង្គជំនុំជម្រះ[28]។ ជនជាប់ចោទបានធ្វើសេចក្តីថ្លែងការណ៍ពីមុនៗដែលបង្ហាញថា គាត់ នឹងមិនមានចេតនានៅក្នុងការចូលរួមជាមួយនឹងតុលាការនេះទេ ហើយក៏បានចោទសួរទៅលើ

---

[24] ប្រតិចារឹក ចុះថ្ងៃទី១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៧៣, ៧៤-៧៥, ៧៦។

[25] ប្រតិចារឹក ចុះថ្ងៃទី១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៧៨-៨០ (យោងទៅលើវិធាន ៦៣(៣)(ខ)(១) និង(២) នៃវិធានផ្ទៃក្នុង)។

[26] ប្រតិចារឹក ចុះថ្ងៃទី១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ៧៦-៧៧។

[27] ប្រតិចារឹក ចុះថ្ងៃទី១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៨០។

[28] ប្រតិចារឹក ចុះថ្ងៃទី១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៨១-៨២។

ធម្មានុភាពនៃកិច្ចដំណើរការនីតិវិធីទាំងនេះផងដែរ[29]។ ចុងក្រោយ សហព្រះរាជអាជ្ញាអះអាងថា ការដោះលែងជនជាប់ចោទអាចបង្កឱ្យមានការរំខានដល់ សណ្តាប់ធ្នាប់សាធារណៈ[30]។

## ៤. សំអាងហេតុ

### ៤.១. ច្បាប់ជាធរមាន

13. អនុលោមតាមវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុង ការឃុំខ្លួនបណ្តោះអាសន្នអាចអនុវត្តទៅបាននៅដំណាក់កាលមុនពេលជំនុំជម្រះ តែនៅពេលដែលមានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះបានប្រព្រឹត្តបទល្មើសដែលមានចែងប៉ុណ្ណោះ ហើយថាការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការចាំបាច់ ប្រសិនបើត្រូវនឹងលក្ខខ័ណ្ឌយ៉ាងហោចណាស់ចំណុចណាមួយនៃបណ្តាចំណុចខាងក្រោម៖

- i) រារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។
- ii) ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង។
- iii) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។
- iv) ការពារសន្តិសុខឱ្យជនដែលត្រូវចោទ ឬ
- v) រក្សាសណ្តាប់ធ្នាប់សាធារណៈ[31]។

14. វិធាន ៨២(១) នៃវិធានផ្ទៃក្នុង ចែងបន្ថែមទៀតថា ក្នុងករណីដែលជនជាប់ចោទត្រូវបានឃុំខ្លួននៅពេលចូលខ្លួនលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទត្រូវស្ថិតនៅក្នុងឃុំដដែលរហូតដល់ពេលសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូងត្រូវបានសម្រេចសេចក្តី។ ទោះបីជាយ៉ាងណាក៏ដោយ ជនជាប់ចោទអាចស្នើសុំឱ្យអង្គជំនុំជម្រះដោះលែងគាត់ ដោយផ្អែកទៅលើការប្រែប្រួលស្ថានភាព[32]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា នៅពេលរឿងក្តីមួយត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង មានគោលការណ៍សន្មតថា លក្ខខណ្ឌដែលត្រូវបានពិចារណាដោយ

---

[29] ប្រតិចារឹក ចុះថ្ងៃទី១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៨២។

[30] ប្រតិចារឹក ចុះថ្ងៃទី១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៨៣-៨៤។

[31] "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ" ឯកសារលេខ E50/3/1/4 កថាខណ្ឌ ៣៩។

[32] វិធាន ៨២(៤) នៃវិធានផ្ទៃក្នុង។

សហចៅក្រមស៊ើបអង្កេតដើម្បីធ្វើយុត្តិកម្មលើការឃុំខ្លួនបណ្តោះអាសន្ននោះ នៅតែបន្តយកមកអនុវត្ត[33]។ ទោះបីជាគោលការណ៍សន្មតនេះត្រូវបានបដិសេធក៏ដោយ ក៏វាជា "បន្ទុករបស់ជនជាប់ចោទក្នុងការតវ៉ាប្រឆាំងទៅនឹងមូលដ្ឋាននៃការឃុំខ្លួន តាមការស្នើសុំទៅអង្គជំនុំជម្រះសាលាដំបូង"[34]។

15. នៅពេលការឃុំខ្លួននៅតែបន្តអំឡុងពេលសវនាការករណីយុត្តិសាស្ត្រតម្រូវឱ្យតុលាការធានាឱ្យបានថា ការឃុំខ្លួននៅតែមានលក្ខណៈសមាមាត្រទៅនឹងកាលៈទេសៈនានានៃរឿងក្តីនោះ រួមទាំងភាពស្មុគស្មាញ និងការវិនិច្ឆ័យសេចក្តីដែលនឹងកើតឡើង។ សនិទានភាពសម្រាប់បន្តការឃុំខ្លួនជនជាប់ចោទ ត្រូវតែថ្លឹងថ្លែងតទល់នឹងហានិភ័យនៃការដកហូតសិទ្ធិសេរីភាពរយៈពេលយូរ ឬគ្មានពេលកំណត់ដោយមិនសមហេតុផល[35]។ ភាពសមហេតុផលនៃការបន្តការឃុំខ្លួន ត្រូវបានវាយតម្លៃដោយពិចារណាលើកាលៈទេសៈនានានៃរឿងក្តីនីមួយៗ ហើយភាពសមហេតុផលនៃការបន្តការឃុំខ្លួននេះ អាចត្រូវធ្វើយុត្តិកម្មបាន ប្រសិនបើមានការបង្ហាញឱ្យឃើញអំពីផលប្រយោជន៍សាធារណៈពិតប្រាកដក្នុងការបន្តឃុំខ្លួន ដែលផលប្រយោជន៍នេះសំខាន់ជាងកាតព្វកិច្ចក្នុងការគោរពសិទ្ធិសេរីភាពបុគ្គល[36]។ អង្គជំនុំជម្រះត្រូវតែពិចារណាថាតើ ផ្នែកពាក់ព័ន្ធរបស់តុលាការបានបង្ហាញអំពីការខិតខំប្រឹងប្រែងក្នុងការអនុវត្តកិច្ចដំណើរនីតិវិធីនេះដែរឬយ៉ាងណា[37]។

---

[33] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ឯកសារលេខ E50/3/1/4 កថាខណ្ឌ ៤៩។

[34] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ឯកសារលេខ E50/3/1/4 កថាខណ្ឌ ៤៨។

[35] សេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E138/1/10 ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២ កថាខណ្ឌ២២ ជើងទំព័រ ៥៦។

[36] *W. តទល់នឹង ប្រទេសស្វីស* សាលក្រមតុលាការសិទ្ធិមនុស្សសហភាពអឺរ៉ុប ECtHR (លេខ ១៤៣៧៩/៨៨) ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៣ កថាខណ្ឌ៣០។ *Muradkhanyan តទល់នឹង Armenia* សាលក្រមរបស់តុលាការសិទ្ធិមនុស្សសហភាពអឺរ៉ុប ECtHR (លេខ ១២៨៩៥/០៦) ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ៨០ (កត់សម្គាល់ផងដែរអំពីសច្ចាធារណ៍និរទោស)។

[37] *W. តទល់នឹង ប្រទេសស្វីស*។ *Muradkhanyan តទល់នឹង Armenia*។ *សូមមើលផងដែរ* សេចក្តីសម្រេច អ.ប.ជ លើបណ្តឹងសាទុក្ខទាក់ទិននឹងសំណើសុំឱ្យដោះលែង កថាខណ្ឌ៧០ *ដកស្រង់ពី រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lubanga* អង្គបុរេជំនុំជម្រះនៃតុលាការ ICC (សំណុំរឿងលេខ ICC-01/04-01/06), សេចក្តីសម្រេចលើបណ្តឹងសុំឱ្យដោះលែង Thomas Lubanga Dyilo បណ្តោះអាសន្ន ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ទំព័រ ៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mrksic និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (សំណុំរឿងលេខ IT-95-13/1-PT), សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំឱ្យដោះលែងបណ្តោះអាសន្ន ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៥ កថាខណ្ឌ២៥។ *សូមមើលផងដែរ* សេចក្តីសម្រេចលើកទីពីររបស់ អ.ប.ជ លើបណ្តឹងសាទុក្ខទាក់ទិននឹងសំណើសុំឱ្យដោះលែង កថាខណ្ឌ ៤៤។

## ៤.២ ការពិនិត្យមើលឡើងវិញអំពីសនិទានភាពសម្រាប់ការបន្តការឃុំខ្លួន

16. លក្ខខណ្ឌដំបូង ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង (វិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង៖ *មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើស)* មិនត្រូវបានលើកឡើងជំទាស់ដោយភាគីណាមួយឡើយ។ សេចក្តីសន្និដ្ឋាននេះផ្អែកលើដីកាដំណោះស្រាយមួយ ដែលត្រូវបានតម្កល់ដោយអង្គបុរេជំនុំជម្រះ ហើយអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការសន្មតដែលថា លក្ខខណ្ឌតម្រូវនេះត្រូវតែបំពេញឲ្យបាននោះ នៅតែបន្តអនុវត្ត។

17. នៅក្នុងដំណាក់កាលស៊ើបអង្កេតទាំងមូល សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ យល់ឃើញថា ការឃុំខ្លួន ខៀវ សំផន គឺជាការចាំបាច់ដើម្បីការពារសុវត្ថិភាពគាត់ រក្សាសណ្តាប់ធ្នាប់សាធារណៈ និងធានាឲ្យមានវត្តមានរបស់គាត់នៅពេលជំនុំជម្រះ[38]។

18. នៅខែ កុម្ភៈ ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃសាជាថ្មីលើមូលហេតុគាំទ្រការបន្តការឃុំខ្លួនជនជាប់ចោទ អនុលោមតាមវិធាន ៨២ នៃវិធានផ្ទៃក្នុង និងបានយល់ឃើញថា ការបន្តការឃុំខ្លួន គឺនៅតែជាការចាំបាច់ដើម្បីធានាវត្តមានរបស់ជនជាប់ចោទ ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ប៉ុន្តែអង្គជំនុំជម្រះបានបដិសេធចោលមូលហេតុទាំងអស់ផ្សេងទៀតដែលគាំទ្រដល់ការបន្តការឃុំខ្លួន[39]។

19. ចាប់តាំងពីពេលនោះ អ.ជ.ត.ក បានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងត្រូវពិចារណាផងដែរថាតើ លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ធ្វើជាយុត្តិកម្មដល់ការឃុំខ្លួនជនជាប់ចោទ ដូចមានចែងនៅក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញដែរ ឬយ៉ាងណា[40]។ អង្គជំនុំជម្រះតុលាការ

---

[38] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឲ្យមានសេរីភាព និងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ឯកសារ C26/5/26 ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៨ (“សាលដីការបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ទាក់ទិននឹងសំណើសុំឲ្យដោះលែង”) កថាខណ្ឌ ៤៩, ៥៨, ៦៣។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ឯកសារ C26/9/12 ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១០ កថាខណ្ឌ ៣៤, ៣៥, ៣៨, ៣៩។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/4/14 ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១។ *សូមមើលផងដែរ* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/4/15 ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១។

[39] សេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់ របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ឯកសារ E50 ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៤០។

[40] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ ឯកសារលេខ E50/3/1/4 កថាខណ្ឌ ៥២។

កំពូលកត់សម្គាល់ផងដែរថា មូលដ្ឋានមួយចំនួនក្នុងចំណោមមូលដ្ឋានទាំងនេះដែលមានចែងនៅក្នុងអនុវិធាននោះ និងសម្រាប់ធ្វើជាយុត្តិកម្មបន្តការឃុំខ្លួន ពោលគឺ ការការពារសន្តិសុខរបស់ជនជាប់ចោទ និងការរក្សានូវសណ្តាប់ធ្នាប់សាធារណៈ មានចែងយ៉ាងច្បាស់នៅក្នុងសេចក្តីសម្រេចពីមុនរបស់អង្គបុរេជំនុំជម្រះ[41]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាកត្តានានាដែលមានចែងនៅក្នុងវិធាន៦៣(៣) នៃវិធានផ្ទៃក្នុង បន្ថែមពីលើការកំណត់ថាតើថិរវេលានៃការឃុំខ្លួនជនជាប់ចោទ មានលក្ខណៈសមស្របនៅក្នុងគ្រប់កាលៈទេសៈដែរ ឬយ៉ាងណា។

### *៤.២.១. ការរារាំងកុំឱ្យជនជាប់ចោទគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ, ការរារាំងកុំឱ្យជនជាប់ចោទត្រូវរូវគ្នាជាមួយនឹងអ្នកសមគំនិត និងការការពារមិនឱ្យជនជាប់ចោទបំផ្លាញភ័ស្តុតាង (វិធាន ៦៣(៣)(ខ)(១) និង(២) នៃវិធានផ្ទៃក្នុង)*

20. សំណើរបស់សហព្រះរាជអាជ្ញាពឹងផ្អែកទាំងស្រុងលើភ័ស្តុតាងមួយចំនួន ដែលនៅឆ្នាំ២០១០ ក្នុងអំឡុងពេលកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង០០២ សមាជិកគ្រួសារមួយរូបរបស់ជនជាប់ចោទ ខៀវ សំផន បានទាក់ទងជាមួយសាក្សីមួយរូប នៅពេលខ្លួនត្រូវបានហាមឃាត់មិនឱ្យធ្វើដូច្នេះ ទោះបីជាមិនមានភាពច្បាស់លាស់ថាតើ ជនជាប់ចោទជាអ្នករៀបចំធ្វើដូច្នេះ ឬបានដឹងអំពីការប្រព្រឹត្តតាមវិធីបែបនេះក៏ដោយ។ អំឡុងកិច្ចដំណើរការនីតិវិធីសវនាការ មិនមានការបង្ហាញណាមួយដែលថា ខៀវ សំផន ឬអ្នកដែលបានធ្វើសកម្មភាពក្នុងនាមជនជាប់ចោទរូបនេះ បានព្យាយាមបំផ្លាញភ័ស្តុតាងនោះឡើយ។ អង្គជំនុំជម្រះសាលាដំបូងមិនយល់ឃើញថា បញ្ហានេះផ្តល់ជាមូលហេតុឱ្យមានការជឿជាក់ថា ខៀវ សំផន អាចព្យាយាមគាបសង្កត់ដល់សាក្សី ប្រសិនបើគាត់ត្រូវបានដោះលែងបណ្តោះអាសន្នដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះឡើយ។

### *៤.២.២. វិធានការដើម្បីធានាបាននូវវត្តមានរបស់ជនជាប់ចោទ (វិធាន ៦៣(៣)(ខ)(៣) នៃវិធានផ្ទៃក្នុង)*

21. ការពិចារណាជាបឋមរបស់អង្គជំនុំជម្រះសាលាដំបូងគឺហានិភ័យ ដែលជនជាប់ចោទអាចរត់គេច។ ជនជាប់ចោទយល់ព្រមបង្ហាញវត្តមានក្នុងអំឡុងសវនាការរបស់គាត់ និងគោរពលក្ខខណ្ឌនានាដែលអាចត្រូវបានដាក់ ប្រសិនបើគាត់ទទួលបានការដោះលែងជាបណ្តោះអាសន្ន[42]។ គ្រួសាររបស់

---

[41] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្នាមៗ ឯកសារលេខ E50/3/1/4 កថាខណ្ឌ ១៦, ៥៤។

[42] លិខិតធានារបស់ជនជាប់ចោទ ខៀវ សំផន, ឯកសារ E275.4, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣; ប្រតិចារឹក, ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៦៩។

គាត់គូសបញ្ជាក់ថា ខ្លួននឹងផ្តល់ឱ្យគាត់នូវកន្លែងស្នាក់អាស្រ័យ ការធ្វើដំណើរ និងជួយដល់គាត់ក្នុងការបំពេញលក្ខខណ្ឌនៃការដោះលែង រួមទាំងការបង្ហាញខ្លួនសម្រាប់សវនាការ[43]។ អង្គជំនុំជម្រះកត់សម្គាល់ទៀតថាសំណុំរឿង ០០២/០១ កំពុងចូលដល់ដំណាក់កាលបិទបញ្ចប់ ហើយការមិនបង្ហាញខ្លួនរបស់ជនជាប់ចោទ (ទោះជាដោយចេតនា ឬដោយអចេតនាក្តី) ប្រឈមនឹងការពន្យារពេលចំពោះការបញ្ចប់សំណុំរឿង ០០២/០១ បានឆាប់រហ័ស និងការជំនុំជម្រះក្តីបន្តបន្ទាប់ទៀតឱ្យបានទាំងស្រុង "[...] គឺជាកិច្ចការដែលត្រូវត្រៀមរៀបចំយ៉ាងធំធេង និងភស្តុភារយ៉ាងច្រើនដែលទាក់ទងនឹងជនជាប់ចោទទាំងបួនរូប [បច្ចុប្បន្នមានពីររូប] ដែលអ្នកទាំងនោះភាគច្រើនមានបញ្ហាសុខភាព និងមានដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងច្រើនសន្ធឹកសន្ធាប់ និងក្រុមមេធាវីជាច្រើននាក់"[44]។ អង្គជំនុំជម្រះពុំយល់ឃើញថា ការធានាអះអាងរបស់ជនជាប់ចោទនិងសមាជិកគ្រួសាររបស់គាត់មានភាពគ្រប់គ្រាន់ដើម្បីបំបាត់កង្វល់ទាំងនេះ ឬហានិភ័យ បើទោះជាតិចតួចក៏ដោយ ដែលថាជនជាប់ចោទអាចរត់គេចខ្លួន នៅក្នុងដំណាក់កាលចុងក្រោយនៃសវនាការនេះឡើយ។ អង្គជំនុំជម្រះក៏កត់សម្គាល់ផងដែរថា នៅដំណាក់កាលចុងក្រោយនៃសវនាការនេះ ជនជាប់ចោទអាចពិចារណាដល់ការរត់គេចខ្លួន ថាជាជម្រើសជាក់លាក់មួយនៅពេលដែលប្រឈមនឹងការទទួលទោសក្នុងពន្ធនាគាររយៈពេលវែង ប្រសិនបើគាត់ត្រូវបានរកឃើញថាមានពិរុទ្ធ[45]។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ការពិចារណាទាំងនេះនៅតែជាមូលហេតុដែលមានសុពលភាពដើម្បីបន្តឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន។

### *៤.២.៣. ការការពារសុវត្ថិភាពរបស់ជនត្រូវចោទ និងការថែរក្សាសណ្តាប់ធ្នាប់សាធារណៈ (វិធាន ៦៣(៣)(ខ)(៤) និង(៥) នៃវិធានផ្ទៃក្នុង)*

22. ក្នុងអំឡុងសវនាការកាលពីថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានយោងទៅលើការស្ទាបស្ទង់មតិមួយក្នុងចំណោមមនុស្ស ១០០០ នាក់ ដែលក្នុងនោះមនុស្ស ៤០ ភាគរយបានគូសបញ្ជាក់តាមការយល់ឃើញរបស់ពួកគាត់ថា ពួកគាត់នៅតែមានអារម្មណ៍ចង់សងសឹកចំពោះ

---

[43] *លិខិតបញ្ជាក់* [កោសលប់], ឯកសារ E275.2, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៣; *លិខិតបញ្ជាក់* [កោសលប់], ឯកសារ E275.3, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[44] សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗ ឯកសារលេខ E50/3/1/4 កថាខណ្ឌ ៥៤។

[45] សេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់ របស់ នួន ជា, ខៀវ សំផន និងអៀង ធីរិទ្ធ ឯកសារលេខ E50 ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ៤០, ៤១។

អតីតថ្នាក់ដឹកនាំនៃរបបខ្មែរក្រហម[46]។ សហព្រះរាជអាជ្ញាក៏បានធ្វើការកត់សម្គាល់ផងដែរអំពីការវាយដំមកលើ ខៀវ សំផន ពីសំណាក់ហ្វូងមនុស្សកាលពីឆ្នាំ ១៩៩១។ អង្គជំនុំជម្រះពិចារណាឃើញថា ថ្វីបើអាចមានហានិភ័យចំពោះសុវត្ថិភាពរបស់ជនជាប់ចោទ ខៀវ សំផន ក៏ដោយ មិនមានភស្តុតាងបង្ហាញថា ហានិភ័យនេះនៅមានអត្ថិភាពនោះទេ។ អង្គជំនុំជម្រះពុំមានមូលដ្ឋានដើម្បីសន្និដ្ឋានថា ការបន្តឃុំខ្លួនជនជាប់ចោទ ជាការសមហេតុផលផ្អែកលើគ្រោះថ្នាក់ដែលអាចកើតមានចំពោះរូបគាត់ ឬមួយការដោះលែងរូបគាត់ជាការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈឡើយ។

23. អង្គជំនុំជម្រះក៏យល់ឃើញថា ការបន្តឃុំខ្លួន ខៀវ សំផន មិនមែនមិនសមស្របគ្រប់កាលៈទេសៈទាំងអស់នៃរឿងក្តីនោះទេ។ នៅក្នុងសំណុំរឿងនានាដែលមានភាពស្មុគស្មាញប្រហាក់ប្រហែលទៅនឹងសំណុំរឿង ០០២ ការឃុំខ្លួនរយៈពេល ៥ ឆ្នាំ ឬយូរជាងនេះត្រូវបានចាត់ទុកជាការសមហេតុផលនៅក្នុងគ្រប់កាលៈទេសៈទាំងអស់[47]។ នៅពេលដែលគ្រប់កាលៈទេសៈទាំងអស់ត្រូវបានពិចារណា រួមទាំងការយល់ឃើញ ដែលថា "ការជំនុំជម្រះក្នុងសំណុំរឿងលេខ ០០២ គឺជាកិច្ចការដែលត្រូវត្រៀមរៀបចំយ៉ាងធំធេង និងភស្តុភារយ៉ាងច្រើន" សំណុំរឿង ០០២ បានដំណើរការទៅមុខយ៉ាងរហ័សតាមដែលអាចធ្វើទៅបាន។ បើទោះបីជាក្នុងករណីណាក៏ដោយ និងដោយហេតុថាសំណុំរឿង ០០២/០១ កំពុងឈានទៅរកដំណាក់កាលបញ្ចប់របស់ខ្លួន អង្គជំនុំជម្រះពុំឯកភាពជាមួយការលើកឡើងរបស់មេធាវីការពារក្តី ខៀវ សំផន ដែលថាជនជាប់ចោទខ្វះលទ្ធភាពនៃការប្រមើលឃើញ ឬភាពជាក់លាក់ទាក់ទងនឹងថិរវេលានៃការជំនុំជម្រះនេះឡើយ។ អង្គជំនុំជម្រះ

---

[46] ប្រតិចារឹក ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ E1/180.1 ទំព័រ ៨០។ សំឡេងរបស់អ្នករួចផុតពីសេចក្តីស្លាប់៖ ឥរិយាបថចំពោះ អ.វ.ត.ក, អតីតខ្មែរក្រហម និងបទពិសោធន៍ជាមួយការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី, ឯកសារ E50/3/1/1.1.4, ខែ ធ្នូ ឆ្នាំ ២០១០។

[47] *សំណុំរឿង W. ទល់នឹង* Switzerland, សាលក្រម, តុលាការសិទ្ធិមនុស្សអឺរ៉ុប (លេខ 14379/88), ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៣, កថាខណ្ឌ ៤២; *សូមមើលផងដែរ* ការឃុំខ្លួនជនជាប់ចោទនៅចំពោះមុខតុលាការ ICTY និងតុលាការ ICTR៖ ៥-១០ ឆ្នាំ, ឯកសារ E138/1/9.1, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១២ (*ដោយលើកឡើងអំពី* សំណុំរឿងចំនួន ៨២ នៅតុលាការ ICTR និង ICTY ដែលការឃុំខ្លួនមុនការជំនុំជម្រះមានរយៈពេលលើសពីចំនួន ៥ ឆ្នាំ)។ អនុលោមតាមច្បាប់យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ការឃុំខ្លួនមុនការជំនុំជម្រះគិតចាប់ពីពេលដែលជននោះត្រូវបានឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំង រហូតដល់ពេលមានសាលក្រមរបស់តុលាការសាលាដំបូង (*សូមមើលឧទាហរណ៍ សំណុំរឿង* Punzelt *ទល់នឹង សាធារណរដ្ឋឆែក*, សាលក្រម, តុលាការសិទ្ធិមនុស្សអឺរ៉ុប (លេខ 31315/96), ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០០, កថាខណ្ឌ ៧០) ។ សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗ, ឯកសារលេខ E50/3/1/4 កថាខណ្ឌ ៥៤។

យល់ឃើញថា វិយជការរបស់ជនជាប់ចោទមិនមែនធ្វើឱ្យការឃុំខ្លួនគាត់មិនសមស្របនោះទេ។ កត្តាទាំងឡាយដែលផ្តល់ភាពសមហេតុផលចំពោះការបន្តឃុំខ្លួនគាត់ មានភាពលើសលប់លើកត្តាផ្ទាល់ខ្លួនរបស់ជនជាប់ចោទ នៅពេលដែលអង្គជំនុំជម្រះធ្វើការពិចារណាអំពីបទដ្ឋាននៃការយកចិត្តទុកដាក់ដែលត្រូវបានផ្តល់ទៅឱ្យជនជាប់ចោទ និងការគោរព សិទ្ធិរបស់ជនជាប់ចោទ ដែលត្រូវបានផ្តល់ឱ្យដោយមន្ទីរឃុំឃាំងនៃ អ.វ.ត.ក។ ជាចុងបញ្ចប់ វិធាន ៨២(៤) នៃវិធានផ្ទៃក្នុងអនុញ្ញាតឱ្យជនជាប់ចោទស្នើសុំឱ្យមានការដោះលែង នៅពេលដែលកាលៈទេសៈរបស់គាត់មានការផ្លាស់ប្តូរ បន្ទាប់ពីសំណើសុំចុងក្រោយរបស់គាត់ត្រូវបានបដិសេធ។ អង្គជំនុំជម្រះតុលាការកំពូលបានតម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយបដិសេធមិនដោះលែងជនជាប់ចោទ ខៀវ សំផន កាលពីខែ កុម្ភៈ ឆ្នាំ ២០១១។ អង្គជំនុំជម្រះ បានរកឃើញថា មិនមានការផ្លាស់ប្តូរណាមួយចំពោះកាលៈទេសៈនានារបស់ជនជាប់ចោទ ចាប់ពីពេលនោះមក ដែលអាចធ្វើឱ្យអង្គជំនុំជម្រះផ្តល់ការអនុញ្ញាតតាមសំណើសុំនាពេលនេះឡើយ។

**ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសម្រេច៖**

**បដិសេធ** សំណើសុំដោះលែងជាបន្ទាន់របស់ ខៀវ សំផន

**បង្គាប់** ឱ្យបន្តឃុំខ្លួនជនជាប់ចោទរូបនេះ ស្របតាមវិធាន ៦៣ (៣)(ខ)(៣)។

ភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣

ប្រធានអង្គជំនុំជម្រះសាលាដំបូង

នីល ណុន